55/6

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ: ៥៧

ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣

<u>សាលដីកា</u>

លេខ: ៩៩ "ខ"

ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤

## <u>សាលដីកា</u>

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ ។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោកស្រី [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជី**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

<u>**ដើមចោទ:**</u> ឈ្មោះ [redacted] សុម៉ាលី (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីរាជការ មានទីលំនៅសព្វថ្ងៃភូមិ១ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

មានលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

<u>**ចុងចម្លើយ:**</u> ឈ្មោះ [redacted] ស៊ូអៀង (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ មុខរបរប្រធានសមាគមកាត់ដេរនៅកម្ពុជា មានទីលំនៅសព្វថ្ងៃផ្ទះលេខ៥២៨ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

១៧២

172



Scanned with CamScanner

55/7

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

**កម្មវត្ថុបណ្តឹង:**

-សុំបើកផ្លូវចេញ-ចូលទំហំទទឹង ១០ម ទៅកាន់ដីរបស់ខ្លួនតាមលំនាំដើមទៅកាន់ផ្លូវលេខ២០០៤ ។

-ឲ្យចុងចម្លើយឈ្មោះ [redacted] ស៊ូអៀង ប្រគល់ដីទំហំ ៥០១ម² ស្ថិតនៅផ្លូវលេខ២០០៤ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឲ្យទៅខ្លួនដើម្បីបង្គ្រប់ដីទំហំសរុបចំនួន ៤.០០០ម² គ្រប់គ្រងជាកម្មសិទ្ធិវិញ ។

-ចុងចម្លើយត្រូវរ៉ាប់រងការចំណាយផ្សេងៗក្នុងការបើកច្រកចេញ-ចូលវិញ ។

-ចុងចម្លើយត្រូវរ៉ាប់រងពន្ធលើពាក្យបណ្តឹង និងពន្ធប្រាក់ប្រដាប់ក្តីតុលាការក្រៅពន្ធ ។

**អំពីអង្គហេតុ និង ចំណុចវិវាទ**

**ក.អំពីអង្គហេតុ ជាមូលហេតុនៃការទាមទារ:**

តាមពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ និងពាក្យបណ្តឹងបន្ថែម ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ របស់ដើមចោទឈ្មោះ [redacted] សុម៉ាលី បានបញ្ជាក់ថា៖ កាលពីមុនដីទំហំ ១០ម ស្ថិតនៅភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៥ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ គឺជាក្លឹភ្លោះ " ផ្លូវដើរ " ស្ថិតនៅផ្នែកខាងកើតដីខ្លួនដែលប្រជាពលរដ្ឋដែលនៅជុំវិញខ្លួន ហើយនៅឆ្នាំ២០០៦ ចុងចម្លើយបានចាក់ដីលុបក្លឹភ្លោះនោះធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ព្រមទាំងធ្វើរបងបិទផ្លូវ ធ្វើឲ្យខ្លួនមិនអាចចេញចូលទៅកាន់ដីនោះបាន ។ ករណីនេះ ខ្លួនបានប្តឹងទៅអាជ្ញាធរដែនដី និងសុរិយោដីរាជធានីភ្នំពេញ រហូត តែពុំឃើញមានដំណោះស្រាយ ម្យ៉ាងទៀត តាមការចុះពិនិត្យទីតាំងដីទំនាស់ជាក់ស្តែងកាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១១ ឃើញថា ដីរបស់ខ្លួនបាត់បង្គោលព្រំដីអស់ និងឃើញដីខ្លួនរួមតូចជាងមុន ហើយខ្លួនអញ្ជើញជំនាញសុរិយោដីចុះទៅវាស់តាមលក្ខណៈបច្ចេកទេសឃើញថា ដីខ្លួនមានទំហំ ៤.០០០ម² បែរជានៅសល់ទំហំ ៣.៤៩៩ម² បាត់អស់ទំហំ ៥០១ម² ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០២ក្រ.២ (យ) ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១-ក/បើកច្រកផ្លូវចេញ-ចូលទំហំទទឹង ១០ម៉ែត្រ គិតចាប់ពីព្រំដីផ្នែកខាងលិចនៃដីរបស់ដើមចោទឈ្មោះ [redacted] សុម៉ាលី ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ភ្ជាប់ទៅកាន់ផ្លូវបេតុងស្ថិតនៅព្រំដីផ្នែកខាងលិចដែលមានស្រាប់ ភាគីចុងចម្លើយឈ្មោះ [redacted] ស៊ូអៀង បានសាងសង់ ដើម្បីចេញ-ចូលទៅកាន់ផ្លូវលេខ២០០៤ ទុកជាផលប្រយោជន៍ប្រើប្រាស់រួមគ្នាសំរាប់ចេញ-ចូលទៅកាន់ដីកម្មសិទ្ធិរៀងៗខ្លួនជាថ្នូរជំនួសឲ្យដីក្លឹភ្លោះផ្លូវចេញ-ចូល ជាប់ព្រំដីផ្នែកខាងកើតដីរបស់ដើមចោទបាន ប្រើប្រាស់សំរាប់ចេញ-ចូលទៅកាន់ផ្លូវលេខ២០០៤ នាពេលកន្លងមក ។

ខ/ឲ្យភាគីដើមចោទឈ្មោះ [redacted] សុម៉ាលី ជួយចេញថ្លៃផ្លូវបេតុងដូចខាងលើស្មើតំលៃ ១/៣ នៃតំលៃជាក់ស្តែងដែលភាគីចុងចម្លើយឈ្មោះ [redacted] ស៊ូអៀង បានចំណាយសាងសង់ពេលកន្លងមក ។

គ/ឲ្យភាគីចុងចម្លើយឈ្មោះ [redacted] ស៊ូអៀង ត្រូវប្រគល់ដីទំហំ ៨០២ម² ដូចក្នុងលិខិតលេខ ១១៦៦ ជនសសបទ ចុះថ្ងៃទី៣០-១១-២០១១ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ ដែលទំហំដីត្រូវប្រគល់នោះ ត្រូវស្ថិតនៅតាមព្រំដីជាប់ព្រំដីកម្មសិទ្ធិរបស់ដើមចោទឈ្មោះ [redacted] សុម៉ាលី មានទីតាំងស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលចុងចម្លើយបានកាន់កាប់លើស នាពេលកន្លងមក ប្រគល់ឲ្យភាគីដើមចោទវិញ ដើម្បីបង្គ្រប់ចំនួន ៤.០០០ម² = ៤០អា ដូចមានក្នុងលិខិតផ្ទេរអំណោយផ្តាច់ ចុះថ្ងៃទី១៧-៧-២០០៦ រវាងឈ្មោះ [redacted] សុវុឌ្ឍ ជាមួយឈ្មោះ [redacted] សុម៉ាលី និងតាមបង្កាន់ដៃទទួលពាក្យលេខ ១៩៩៩២ ចុះថ្ងៃទី៣១-១២-១៩៩០ របស់ការិយាល័យកសិកម្មស្រុក ។ ការអនុវត្តប្រគល់ដីតាមទំហំជាក់ស្តែងរបស់ចុងចម្លើយដូចខាងលើឲ្យទៅចុងចម្លើយវិញ ត្រូវធ្វើយ៉ាងណាឲ្យរក្សាបានស្ថានភាពនូវទ្រង់ទ្រាយរូបរាងដីដូចក្នុងប្លង់បង្ហាញទីតាំងដីទំនាស់រវាងឈ្មោះ [redacted] សុម៉ាលី និងឈ្មោះ [redacted] ស៊ូអៀង លេខ២៦/១១ បទ ចុះថ្ងៃទី៣០-១១-២០១១ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញតទៅ ។

ផ្អែកតាមមាត្រា ១៤២ ,១៥២ ,១៥៣ ,១៥៤ នៃច្បាប់ភូមិបាល និងមាត្រា ២៩០ ,២៩៣ នៃក្រមរដ្ឋប្បវេណី ។

២-ប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងៗជាបន្ទុកចុងចម្លើយ ។

តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៣-សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៩៣ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ របស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] ស៊ូអៀង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០២ក្រ.២(យ) ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៧ក្រ VI (យ) ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ច្រានចោលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧-០៣-២០១២ របស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីចុងចម្លើយឈ្មោះ [redacted] ស៊ូអៀង ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០២ក្រ.២(យ) ចុះថ្ងៃទី១០-០២-២០១២ របស់



១៧៤

៧៥

Scanned with CamScanner

សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ ។

៤-សាលដីកានេះ ប្រកាសជាសាធារណៈនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ ។

-បើកផ្លូវប្តឹងសាទុក្ខរយៈពេល ១ខែ ក្រោយពីបានទទួលលិខិតជូនដំណឹងអំពីសាលដីកានេះ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១០ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣ របស់លោក [redacted] ជាតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] ស៊ូអៀង ប្តឹងមិនសុខនឹងសាលដីការដ្ឋប្បវេណី លេខ ២៧ក្រ VI (យ) ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**ខ.អំពីសេចក្តីថ្លែងការណ៍របស់គូភាគីៈ**

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] ស៊ូអៀង បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា៖ ដើមចោទបានប្តឹងកូនក្តីខ្ញុំមកសាលាដំបូងរាជធានីភ្នំពេញ ដោយទាមទារឲ្យតុលាការចេញសាលក្រមទី១ សុំបើកច្រកចេញ-ចូលទំហំ ១០ម៉ែត្រ ទៅកាន់ដីរបស់ខ្លួនតាមលំនាំដើម និងទី២ គឺចុងចម្លើយជាអ្នកទទួលបន្ទុកបើកផ្លូវតាមរយៈពាក្យបណ្តឹងចុះថ្ងៃទី៣០-១២-២០១០ ដោយបញ្ជាក់ថា ដីសុំបើកផ្លូវនេះ គឺជាភ្លឺភ្លោះដែលមានតាំងពីដើម ប៉ុន្តែចុងចម្លើយបានចាក់ដីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ដែលជាហេតុនាំឲ្យដើមចោទមិនអាចចេញចូលទៅកាន់ដីរបស់ខ្លួនបាន ។ បន្ទាប់មកទៀត ដើមចោទបានដាក់ពាក្យសុំកែតម្រូវ ចុះថ្ងៃទី១១-០៣-២០១១ ដែលមានខ្លឹមសារថា ការសុំបើកផ្លូវ ១០ម៉ែត្រ នេះមានទីតាំងស្ថិតនៅផ្លូវលេខ២០០៤ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងចុងក្រោយបានធ្វើពាក្យបណ្តឹងបន្ថែម ចុះថ្ងៃទី២៦-៥-២០១១ ដែលមានខ្លឹមសារថា បង្គាប់ឲ្យចុងចម្លើយប្រគល់ដីទំហំ ៥០១ម៉ែត្រការ៉េ មកឲ្យដើមចោទ ដោយបញ្ជាក់ថា នៅពេលដើមចោទវាស់ជាក់ស្តែង គឺដីរបស់ខ្លួននៅសល់មានទំហំ ៣៩៩៩ម៉ែត្រការ៉េ គឺបាត់ដីអស់ទំហំ ៥០១ម៉ែត្រការ៉េ ។

សាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូងរាជធានីភ្នំពេញ គឺជាសេចក្តីសម្រេចផ្ទុយច្បាប់ ដោយហេតុថា៖

ទី១-ការយកមាត្រានៃក្រមរដ្ឋប្បវេណីមកប្រើសម្រាប់សំណុំរឿងនេះ គឺផ្ទុយនឹងមាត្រា ០៥ នៃច្បាប់ស្តីពីការអនុវត្តក្រម ពីព្រោះបញ្ហានេះ កើតឡើងក្នុងច្បាប់ចាស់ គប្បីយកច្បាប់ភូមិបាលឆ្នាំ២០០១ មកប្រើទើបត្រឹមត្រូវ

ទី២-អ្នកសុំសេវភាពជាអ្នកចេញសោហ៊ុយ (មាត្រា ១៥២ នៃច្បាប់ភូមិបាល)

ទី៣-ដើមចោទថា បាត់ដី ប៉ុន្តែគ្មានភស្តុតាងគាំទ្រ លើកលែងភស្តុតាងដែលត្រូវបានស្វែងរកដោយសាលាដំបូងរាជធានីភ្នំពេញ ។



Scanned with CamScanner

55/4

នីតិវិធីនៃការជំនុំជំរះរបស់សាលាដំបូងរាជធានីភ្នំពេញ គឺផ្ទុយច្បាប់ ដោយហេតុថា៖

ទី១-សាលាដំបូងដើរតួនាទីជាតុលាការរដ្ឋប្បវេណីសកម្ម

ទី២-សម្រេចសេចក្តីចំពោះចំណុចដែលដើមចោទមិនបានសុំ

ទី៣-សម្រេចសេចក្តីមិនផ្អែកទៅលើភស្តុតាងដែលមានក្នុងសំណុំរឿង

-សាលដីការបស់សាលាឧទ្ធរណ៍ គឺសម្រេចផ្ទុយច្បាប់ ។

-ការទាមទាររបស់ដើមចោទមិនអាចទទួលស្គាល់បានឡើយ តាមច្បាប់សារធាតុដោយហេតុថា៖

ទី១-នត្ថិភាពនៃសេរភាពតាមលំនាំដើម (ការអះអាងរបស់ដើមចោទ)

ទី២-ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចេញឲ្យតែកម្មសិទ្ធិករស្របច្បាប់

ទី៣-លិខិតសុរិយោដី គឺជាលិខិតគតិយុត្តិ ។

<u>**សំណូមពរ៖**</u>

-សំណើសុំតុលាការកំពូល សម្រេចសេចក្តីខ្លួនឯងដោយមិនបង្វិល និងបដិសេធសេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញនិងសាលាឧទ្ធរណ៍

-សំណើសុំបដិសេធសាលក្រមរដ្ឋប្បវេណីលេខ ០២ក្រ២(យ) ចុះថ្ងៃទី១០-០២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ

-សំណើសុំបដិសេធសាលដីការដ្ឋប្បវេណីលេខ ២៧ក្រVI (យ)ចុះថ្ងៃទី០៤-៩-២០១២។

លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] សុម៉ាលី បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា: កាលពីឆ្នាំ១៩៨៩ អង្គភាពឃ្លាំងរថយន្ត K4 បានធ្វើការបែងចែកដីធ្លីឲ្យប្រជាពលរដ្ឋ ដែលជាបុគ្គលិកធ្វើការនៅទីនោះ ហើយដីដែលបានបែងចែកនោះជាប្រភេទដីស្រែ ពេលនោះបងប្រុសបង្កើតរបស់កូនក្តីខ្ញុំឈ្មោះ [redacted] សុវុឌ្ឍ ក៏បានទទួលដីស្រែទំហំ ៤០អា ហើយដីនោះត្រូវធ្វើដំណើរចេញចូលទៅធ្វើស្រែតាមច្រកពីរ គឺតាមភ្លឺភ្លោះ និងតាមភ្លឺស្រែ ។ មកដល់ឆ្នាំ២០០៦ បងប្រុសកូនក្តីខ្ញុំក៏បានធ្វើអំណោយឲ្យប្អូនស្រី ចាន់ សុម៉ាលី , លុះក្រោយមកទៀត មានឈ្មោះ [redacted] ស៊ូអៀង ដែលជាចុងចម្លើយបានទិញដីជុំវិញតំបន់នោះ ហើយក៏ចាក់ដីបំពេញ លុបភ្លឺស្រែ ចាក់បេតុងធ្វើឲ្យកូនក្តីខ្ញុំគ្មានផ្លូវចេញចូលទេ ព្រមទាំងចាក់ដីមានកំពស់ខ្ពស់ធ្វើឲ្យដីកូនក្តីខ្ញុំដូចថ្លុកត្រពាំង និងមានត្រកួនដុះពេញ ។

ក្នុងរឿងនេះ នាងខ្ញុំសូមរៀបរាប់នូវអង្គហេតុពិត ដែលមានសាក្សីឈ្មោះ [redacted] ស្មាលីន ដែលគាត់បានបែងចែកដីឲ្យឈ្មោះ [redacted] សុវុឌ្ឍ ,សាក្សីឈ្មោះ [redacted] សុផារី ជាអ្នកធ្វើស្រែឲ្យកូនក្តីខ្ញុំ ដែលធ្លាប់បានដឹកស្រូវតាមផ្លូវពីរនេះ និងសាក្សីឈ្មោះ [redacted] សុខា ដែលជាអ្នកធ្វើស្រែនៅក្បែរនោះ ជាពិសេសគឺសាក្សីឈ្មោះ [redacted] សុវុឌ្ឍ បានបំភ្លឺឲ្យតុលាការគ្រប់ជាន់ថ្នាក់ក្នុងនាមខ្លួនជាអ្នកបានធ្វើអំណោយដីឲ្យទៅប្អូនស្រីឈ្មោះ [redacted] សុម៉ាលី ដែលជាកូនក្តីខ្ញុំ ។

តាមការលើកឡើងខាងលើរបស់នាងខ្ញុំដែលជាមេធាវីតំណាងឲ្យឈ្មោះ [redacted] សុម៉ាលី



Scanned with CamScanner

នេះ គឺជាសំអាងហេតុក្នុងការទាមទាររបស់កូនក្តីខ្ញុំ និងសម្រាប់ឲ្យតុលាការធ្វើការពិនិត្យពិចារណា ដើម្បីធ្វើការសម្រេចលើរឿងក្តីនេះឲ្យបានត្រឹមត្រូវតាមច្បាប់ ។ ដែលផ្ទុយពីអ្វីដែលជាការលើកឡើងរបស់ឈ្មោះ [redacted] ស៊ូអៀង គ្រាន់តែជាលេសដោះសារប៉ុណ្ណោះ ។

ទើបក្នុងករណីនេះ នាងខ្ញុំសូមបញ្ជាក់ជូនថា:

ផ្អែកតាមមាត្រា ១២៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា ប្រសិនបើតុលាការពុំអាចសម្រេចថា ត្រូវទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលគូភាគីបានស្នើសុំឲ្យពិនិត្យ ឬបើយល់ឃើញថា មានការចាំបាច់ផ្សេងទៀត នោះតុលាការអាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន ។

និងតាមមាត្រា ១៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា តុលាការអាចប្រគល់កិច្ចការស្រាវជ្រាវដែលចាំបាច់ទៅស្ថាប័នក្នុងប្រទេស ឬស្ថាប័នបរទេសបាន ។

យោងតាមបញ្ញត្តិច្បាប់ខាងលើនេះ ចៅក្រមមានសិទ្ធិចុះទៅដល់ទីតាំងវិវាទធ្វើកំណត់ហេតុចុះពិនិត្យទីតាំងទំនាស់ និងចេញលិខិតទៅស្ថាប័នជំនាញឲ្យបំភ្លឺ ឬផ្តល់ឯកសារបន្ថែម ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ និងមានភាពច្បាស់លាស់ បន្ថែមពីលើភស្តុតាងរបស់ភាគីដែលបានបង្ហាញមកតុលាការ សម្រាប់ឲ្យតុលាការធ្វើការសម្រេចសេចក្តីប្រកបទៅដោយភាពត្រឹមត្រូវ និងយុត្តិធម៌ជូនភាគីវិវាទ ។

**សំណូមពរ:** សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទាំងមូល ។

លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] សុម៉ាលី បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា: នាងខ្ញុំឯកភាពតាមការសន្និដ្ឋានរបស់សហភាគី និងសុំបន្ថែមលើទំហំដីដែលបានបាត់ គឺការបាត់បង់ដីដែលមានទំហំ ៥០២ម៉ែត្រការ៉េ នោះកូនក្តីនាងខ្ញុំមានឯកសារពីចៅសង្កាត់ជាអំណះអំណាង និងមានការសម្រេចសេចក្តីពីសាលាដំបូងរាជធានីភ្នំពេញ ឲ្យភាគី [redacted] ស៊ូអៀង ប្រគល់មកឲ្យកូនក្តីខ្ញុំដើម្បីបង្គ្រប់ដីចំនួន ៥.០០០ម៉ែត្រការ៉េ វិញ ,ដូច្នេះកូនក្តីនាងខ្ញុំអាចទទួលយកបានព្រោះជាលទ្ធផលរបស់ស្ថាប័នជំនាញ ដែលបានធ្វើការវាស់វែងជាផ្លូវការទៅតាមលិខិតរបស់សាលាដំបូងរាជធានីភ្នំពេញ ។

**សំណូមពរ:** សុំតំកល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការ ។

-ក្រោយពីស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថា: បណ្តឹងសាទុក្ខលេខ ១០ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣ របស់ចុងចម្លើយ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាម



Scanned with CamScanner

មាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី និងមាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា: ការដែលសាលាដំបូងរាជធានីភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ដែល សម្រេចឲ្យចុងចម្លើយបើកផ្លូវទទឹង ១០ម ដោយតម្រូវឲ្យដើមចោទជួយចេញថ្លៃផ្លូវបេតុង ស្មើតម្លៃ ១/៣ នៃតម្លៃជាក់ស្តែង ដែលចុងចម្លើយបានចំណាយកន្លងមក ដោយសំអាងថា ជាជំនួសឲ្យភ្លឺភ្លោះសំរាប់ចេញចូលជាប់ព្រំដីខាងកើតរបស់ដើមចោទដែលមានពីមុន ហើយបច្ចុប្បន្នបាត់រូបរាងអស់ហើយនោះ តុលាការកំពូល ពិនិត្យឃើញថា ដីរបស់ដើមចោទត្រូវបានប៊ិទជិត និងគ្មានច្រកចេញចូលមកកាន់ផ្លូវសាធារណៈពិតមែន ក៏ប៉ុន្តែការដែលអនុញ្ញាតឲ្យបើកផ្លូវរហូតដល់ទទឹង១០ម គឺនាំឲ្យប៉ះពាល់ច្រើនដល់ផលប្រយោជន៍របស់ចុងចម្លើយ ហើយម្យ៉ាងទៀត ការដែលបង្គាប់ឲ្យចុងចម្លើយបើកផ្លូវតែម្នាក់ឯង ក៏មិនទាន់គ្រប់គ្រាន់នៅឡើយដែរ ពីព្រោះចុងចម្លើយមិនមានដីរហូតទល់ផ្លូវ២០១៤ ទេ គឺដីផ្នែកខ្លះដែលអមច្រកផ្លូវបេតុងជាកម្មសិទ្ធិរបស់អ្នកផ្សេង ។ តាមគំនូសប្លង់ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីបង្ហាញថា ច្រកផ្លូវបេតុងមានទទឹង ៥,២៨ម ប៉ុន្តែខាងចុងចម្លើយថាមានទទឹងរហូតដល់ ៨ម ។

-ការដែលឲ្យចុងចម្លើយប្រគល់ដីទំហំ ៤០២ម² ស្ថិតនៅតាមព្រំដីជាប់ព្រំដីកម្មសិទ្ធិរបស់ដើមចោទ ដោយផ្អែកតាមលិខិតលេខ ១១៦៦ ដនសសបទ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ ដោយសំអាងហេតុថា ចុងចម្លើយបានចាក់ដីបំពេញអាចហៀរអាចម៍ដីចូលតាមជុំវិញព្រំដីរបស់ដើមចោទនោះ គឺជាការមិនត្រឹមត្រូវទេ ពីព្រោះលិខិតរបស់ស្ថាប័នជំនាញខាងលើមានសេចក្តីថា " ដីភាគីឈ្មោះ [redacted] សុម៉ាលី មានទំហំ ៣៥៩៨ម² ជាដីមានបង្គោលព្រំថ្ម " ពតិមានអំពីទំហំដីនេះ ស៊ីសង្វាក់គ្នាផងដែរ ទៅនឹងសេចក្តីថ្លែងការណ៍របស់មេធាវីដើមចោទនាពេលសវនាការរបស់តុលាការកំពូល ដែលថា " ដីរបស់កូនក្តីខ្លួនមានបង្គោលចំណាំព្រំដី និងថាពេលវាស់វែងមន្ត្រីជំនាញបានកាយអាចម៍ដីចេញ រួចវាស់ផ្អែកតាមបង្គោលព្រំ " ដូចនេះ មានន័យថា ទំហំដី ៣៥៩៨ម² ត្រូវបានរកឃើញដោយការវាស់វែងតាមបង្គោលព្រំរបស់ដើមចោទដែលបានប្រកាន់ហើយ ។ លើសពីនេះទៅទៀត ដើមចោទមិនមានភស្តុតាងអ្វីរឹងមាំលើទំហំដីដែលខ្លួនមានសិទ្ធិនោះទេ គឺមានតែបង្កាន់ដៃទទួលពាក្យសុំកាន់កាប់ដី ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩០ ថាដី ៤០អា តែប៉ុណ្ណោះ ដែលតាមជាក់ស្តែងធ្លាប់ជួបប្រទះ ពតិមានលើទំហំដីដែលចុះក្នុងពាក្យសុំកាន់កាប់គ្រាន់ជាការប្រកាសរបស់អ្នកសុំតែប៉ុណ្ណោះ មិនមានការវាស់វែងដោយអង្គភាពជំនាញទេ ដូច្នេះ មិនមានភាពទៀតទាត់ឡើយ ។

-យល់ឃើញថា: គូភាគីមិនបានមកចូលរួមសវនាការនេះទេ ប៉ុន្តែមេធាវីរបស់គូភាគីមានវត្តមានហើយ ដូច្នេះតុលាការកំពូល អាចជំនុំជំរះបាន ។

55/1

-យល់ឃើញថាៈ សាលដីការដ្ឋប្បវេណីលេខ ២៧ ក្រ VI (ឃ) ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ មិនត្រឹមត្រូវនឹងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ ១០ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣ របស់ចុងចម្លើយ ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ២៧ក្រ VI (ឃ) ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៥៧ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-សាលដីកានេះ ជំនុំជំរះ នៅថ្ងៃទី២៧ ខែកុម្ភៈ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤ ។

ឯកឧត្តម [redacted] ប្រធាន
លោកស្រី [redacted] ចៅក្រម
លោក [redacted] ចៅក្រម
លោក [redacted] ចៅក្រម
លោក [redacted] ចៅក្រម
លោកស្រី [redacted] ក្រឡាបញ្ជី

---

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៤

ប្រធាន

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

តុលាការកំពូល

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]